# សេចក្តីសង្ខេបអំពីអាងទន្លេសេសាន

ទន្លេសេសាន គឺជាដៃទន្លេឆ្លងដែនដ៏សំខាន់មួយនៃទន្លេមេគង្គ ដែលហូរកាត់ប្រទេសកម្ពុជា និងវៀតណាម។ អាងទន្លេនេះមានក្រឡាផ្ទៃ 18.800គ.ម$^2$ និងស្ថិតនៅចន្លោះរវាងអាងទន្លេសេកុងនៅភាគខាងជើង និងអាងទន្លេស្រែពកនៅខាងត្បូង។ អាងទន្លេទាំងបីនេះរួមជាមួយគ្នាបង្កើតបានជាអាងទន្លេ 3S និងបង្កើតជាទីជម្រាលឆ្លងដែនធំជាងគេ និងសំខាន់បំផុតនៃទន្លេមេគង្គ ដែលផ្តល់ធារទឹករហូតដល់ 20% នៃធារទឹកសរុបប្រចាំឆ្នាំរបស់ទន្លេមេគង្គ និងហូរនាំល្បាប់ដែលទ្រទ្រង់ដល់សារពាង្គកាយមានជីវិតប្រមាណ15%ទៅទន្លេមេគង្គ។

## ទិដ្ឋភាពទូទៅ




*ទីតាំងអាងទន្លេសេសាននៅក្នុងអាងទន្លេ 3S*

អាងទន្លេសេសាន គ្របដណ្តប់ផ្ទៃដីទំហំតិចជាងមួយភាគបួននៃអាងទន្លេ 3S។ ប៉ុន្តែ ទោះបីមានទំហំតូចក៏ដោយ អាងទន្លេសេសាន មានប្រព័ន្ធអេកូឡូស៊ីសំខាន់ៗជាច្រើន និងផ្តល់ធនធានធម្មជាតិ និងសេវាប្រព័ន្ធអេកូឡូស៊ីសំខាន់ៗចំពោះប្រជាជនដែលរស់នៅក្នុងអាងទន្លេ និងនៅតាមតំបន់ខ្សែទឹកភាគខាងក្រោមអាងទន្លេនេះ។

ព្រំដែនខាងកើតនៃអាងទន្លេនេះភាគខាងកើតក្នុងប្រទេសវៀត-ណាមស្ថិតនៅរត់តាមបណ្តោយកំពូលជួរភ្នំអាណាម ដែលស្ថិតនៅចម្ងាយ 75គ.មពីឆ្នេរសមុទ្រ។ ចាប់ពីតំបន់ចាប់ផ្តើមនៃក្បាលទឹកទន្លេសេសាន ទន្លេនេះហូរចម្ងាយ 415គ.មនិងហូរមកជួបជាមួយទន្លេស្រែពកនៅកម្ពុជា។

ចាប់ពីទីនោះ ទន្លេទាំងពីរនេះហូររួមគ្នាចម្ងាយ 45គ.ម បន្ថែមទៀតរហូតដល់ទន្លេមេនៃទន្លេមេគង្គ នៅខាងលើទីក្រុងស្ទឹងត្រែង។ អាងទន្លេសេសានត្រួតគ្នាជាមួយខេត្តយ៉ាឡាយ និងកន្ទុំ ក្នុងប្រទេសវៀតណាម និងរតនៈគិរី និងស្ទឹងត្រែងក្នុងប្រទេសកម្ពុជា។

| អថេរ | ប្រទេស | |
|---|---|---|
| | កម្ពុជា | វៀតណាម |
| ក្រឡាផ្ទៃអាង (គ.ម$^2$) | 7.566 | 11.255 |
| ប្រវែងបណ្តោយអាង (គ.ម) | 130 | 140 |
| ប្រវែងទទឹងអាង (គ.ម) | 90 | 120 |
| ប្រវែងទន្លេ (គ.ម) | 225 | 237 |
| ចន្លោះរយៈកម្ពស់ (ម) | 56 - 1.434 | 129 – 2.390 |
| រយៈកម្ពស់មធ្យម (ម) | 273 | 778 |
| ចំណោតមធ្យម (អង្សា) | 6 | 10 |
| ខេត្ត | រតនៈគិរី ស្ទឹងត្រែង | យ៉ាឡាយ កន្ទុំ |
| ទីក្រុងធំៗ | បានលុង វើនសៃ | កន្ទុំ ភ្លេយគូ |
| ប្រជាជន (2012) | 95.600 | 896.810 |
| ដង់ស៊ីតេប្រជាជន(ន/គ.ម$^2$) | 13 | 80 |
| កម្ពស់ទឹកភ្លៀងមធ្យម(ម.ម) | 1.965 | 2.115 |
| សីតុណ្ហភាពមធ្យម (°C) | 22,6 | 19,3 |
| តំបន់ការពារធម្មជាតិធំៗ<br>ឧ. = ឧទ្យានជាតិ<br>ដ.ធ. = ដែនបម្រុងធម្មជាតិ | ឧ. វិរៈជ័យ | ឧ. ជូម៉ុមរេយ, ដ.ធ. បាក់ភ្លេគូ, ឧ. កុនកាគិញ, ដ.ធ. ញ៉ុកលិញ (កន្ទុំ) |

សហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra
Swiss Agency for Development

BRIDGE

## អាកាសធាតុ

ការធ្លាក់ភ្លៀងនៅក្នុងអាងទន្លេសេសាន មានទម្រង់ដូចគ្នានឹងការធ្លាក់ភ្លៀងក្នុងអាងទន្លេ 3Sទាំងមូលដទៃទៀតផងដែរ ដោយសីតុណ្ហភាពទាបជាង និងកម្ពស់ទឹកភ្លៀងខ្ពស់ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយកំណើនរយៈកម្ពស់។

អាងទន្លេសេសាន មានសីតុណ្ហភាពជាមធ្យម 20,6ºC និងកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យម 1.934ម.ម។
ប៉ុន្តែ តួលេខមធ្យមទាំងនេះមិនឆ្លុះបញ្ចាំងភាពខុសគ្នាជាខ្លាំងពីមួយខែទៅមួយខែនៅរយៈកម្ពស់ខុសគ្នានោះឡើយ។
អាកាសធាតុរងឥទ្ធិពលពីខ្យល់មូសុងប្រចាំរដូវ និងមានកម្ពស់ទឹកភ្លៀងខ្ពស់បំផុតរវាងខែកក្កដានិងកញ្ញា។ នៅភាគខាងក្រោមនៃអាងនេះមានកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំប្រមាណ1.900 ម.ម និងតិចជាងជិត 2.500ម.ម នៅចំណុចខ្ពស់បំផុត។[1]
កម្ពស់ទឹកភ្លៀងនេះនាំឲ្យមានជារទឹកហូរយ៉ាងច្រើនដែលកើនពី250ម$^3$/វិនាទី នៅខែមីនាដល់ប្រមាណ 4.500 ម$^3$/វិនាទី នៅខែកញ្ញា។
សីតុណ្ហភាព ប្រែប្រួលខុសគ្នាជាខ្លាំងរវាងអាងខាងលើ និងខាងក្រោម។ នៅជិតភាគខាងក្រោមបំផុតនៃទន្លេសេសាន សីតុណ្ហភាពមានមធ្យម35°C ក្នុងខែក្តៅបំផុត រហូតដល់ខែមីនា និងមេសា។
ផ្នែកនានានៃអាងខាងលើនៃអាងមានសីតុណ្ហភាពត្រជាក់ជាងដែលមានសីតុណ្ហភាពជាមធ្យម 20°C។[2]




*ផែនទីគម្របដីឆ្នាំ 2009។ អាងទន្លេសេសានខាងលើ មានតំបន់យ៉ាងធំជាដីកសិកម្ម។ ទិន្នន័យ GlobCover2009.*

[1] MRC 2009. Lower Mekong Basin Historical Hydro Meteorology database.
[2] Hijmans et al. 2005

## សណ្ឋានដី និងគម្របដី

អាងទន្លេសេសានមានសណ្ឋានដីស្ថិតនៅចន្លោះកណ្តាលនៃអាងទន្លេសេកុងដែលមានសណ្ឋានដីចោទខ្លាំង និងដីខ្ពស់-ទាបអាងទន្លេស្រែពក សេចក្តីពិស្តារចុងក្រោយពីការវិភាគគម្របដីសម្រាប់អាងទន្លេមេគង្គបានធ្វើឡើងនៅឆ្នាំ 2003 និងបានបង្ហាញថាគម្របព្រៃឈើធម្មជាតិគ្របដណ្តប់ជិត 63% នៃអាងទន្លេសេសាន។ តួលេខនេះបានប្រែប្រួល ដោយតំបន់ព្រៃធម្មជាតិខ្លះៗ កំពុងត្រូវបំប្លែងជាចំការ និងសម្រាប់ការប្រើប្រាស់ផ្សេងៗ។[3]

ក្នុងចំណោមអាងទន្លេទាំងបី ទន្លេសេសានបានបាត់បង់ព្រៃឈើច្រើនជាងគេ។ ការសិក្សាថ្មីៗមួយប៉ាន់ស្មានថា 9,5%នៃព្រៃឈើក្នុងអាងទន្លេនេះបានបាត់បង់រវាងឆ្នាំ 2000 និង2012។[4] ភាគច្រើននៃការប្រែប្រួលគម្របដីបានកើតឡើងដោយសារការកាប់ឈើ ការបំប្លែងដីព្រៃធម្មជាតិសម្រាប់ចំការដំណាំឧស្សាហកម្ម និងការពង្រីកដីកសិកម្ម។ ការបង្កើតអាងស្តុកទឹកសម្រាប់ថាមពលវារីអគ្គិសនី និងការស្រោចស្រពបាននាំឲ្យមានការបំប្លែងដីព្រៃ ទៅជាដែនទឹកផងដែរ។

## តំបន់ការពារធម្មជាតិ

តំបន់ការពារធម្មជាតិនៅក្នុងអាងទន្លេសេសាន រួមមាន ឧទ្យានជាតិជូម៉ុមរេយ ឧទ្យានជាតិវិរៈជ័យ ដែនបម្រុងធម្មជាតិបាក់ក្តោ-យគូ និងផ្នែកត្រួតគ្នាតូចៗជាមួយឧទ្យានជាតិកុនកាគិញ និងដែនបម្រុងធម្មជាតិង៉ុកលិញ(កន្ទុំ)។ ឧទ្យានជាតិវិរៈជ័យជាតំបន់ការពារធម្មជាតិធំជាងគេនៅក្នុងអាងទន្លេ 3S ដែលមានទំហំ 3.368គ.ម$^2$ ក្នុងនោះ2.240គ.ម$^2$ ស្ថិតនៅក្នុងអាងទន្លេសេសាន។ ទោះបីវិរៈជ័យទាំងមូលស្ថិតក្នុងប្រទេសកម្ពុជាក៏ដោយ ឧទ្យានជាតិនេះជាប់នឹងឧទ្យានជាតិជូម៉ុមរេយនៃប្រទេសវៀតណាម និងតំបន់ការពារធម្មជាតិដុងអំផាំក្នុងប្រទេសឡាវ។ រួមជាមួយគ្នានេះ តំបន់ទាំងបីនេះបង្កើតជាតំបន់ការពារធម្មជាតិដោយឡែកពីគ្នា ប៉ុន្តែតជាប់គ្នារវាង ប្រទេសទាំងបី។ លើកលែងតែបាក់ក្តោយគូចេញ តំបន់ការពារធម្មជាតិដែលបានរៀបរាប់កត់សំគាល់ទាំងអស់ខាងលើក៏ត្រូវបានចាត់ជាតំបន់ជីវៈចម្រុះសំខាន់ៗ[5] តំបន់សត្វស្លាបសំខាន់ៗ ឬ ជាតំបន់ដែលមានលក្ខណៈទាំងពីរខាងលើបែបនេះផងដែរ។

[3] GMS-Environment Operations Center 2009.
[4] Hansen et al. 2013.
[5] កន្លែងទាំងនេះមានសារៈសំខាន់ជាអន្តរជាតិសម្រាប់អភិរក្សជីវៈចម្រុះតាមរយៈតំបន់ការពារធម្មជាតិ និងវិធីដទៃទៀត និងត្រូវបានកំណត់នៅថ្នាក់ជាតិ តាមលក្ខណៈវិនិច្ឆ័យស្តង់ដា។




*ទំព័រមុន៖ តំបន់ការពារធម្មជាតិ និងការបាត់បង់ព្រៃឈើ (ពណ៌ស្វាយ) ពីឆ្នាំ 2001–2012។ តំបន់ធំៗនៅខាងកើតឧទ្យានជាតិវីរៈជ័យ និង បានលុង ត្រូវបានកាន់កាប់ និងបំប្លែងជាចំការឈើ។ទិន្នន័យ៖ MRC 2009, Hansen et al. 2013, WDPA 2013.*

## ប្រជាជន

ប្រជាជនភាគច្រើនរស់នៅប្រមូលផ្តុំគ្នានៅតាមជ្រលងនានា តាមដងទន្លេនិងតាមទីរួមខេត្តមួយចំនួន។ ប្រជាជនប្រមាណមួយលាននាក់រស់នៅក្នុងអាងទន្លេនេះ ក្នុងនោះ 90% នៅក្នុងប្រទេសវៀតណាម។

ដូចគ្នានេះដែរ ដង់ស៊ីតេប្រជាជនមានភាពខុសគ្នាដោយមានតិចទាបជាង10នាក់/គ.ម$^2$ នៅតាមកន្លែងជាច្រើនក្នុងខេត្តស្ទឹងត្រែង និងរតនៈគិរី និងខ្ពស់ជាង 200នាក់/គ.ម$^2$ នៅខេត្តយ៉ាឡាយក្នុងប្រទេសវៀតណាម។[6] ប្រជាជនភាគច្រើននៅវ័យក្មេងនិងកើនឡើងយ៉ាងឆាប់រហ័ស។ នៅកម្ពុជា ប្រជាជន43% មានអាយុក្រោម15ឆ្នាំ និងត្រូវបានព្យាករណ៍ថាកើនឡើងទ្វេដងរហូតដល់ឆ្នាំ 2060។[7]

## ផលផល និងកសិកម្ម

ផលផលនៅក្នុងអាងទន្លេសេសានគឺជាផ្នែកសំខាន់មួយនៃសេដ្ឋកិច្ច។ នៅក្នុងទន្លេសេសានក្រោម ផលត្រីដែលភាគច្រើនបានពីធម្មជាតិ ត្រូវបានរាយការណ៍ថាកំពុងថយចុះ។ នៅអាងទន្លេសេសានខាងលើក្នុងប្រទេសវៀតណាម តម្លៃសេដ្ឋកិច្ចនៃផលនេសាទបានកើនឡើង ភាគច្រើនដោយសារការវិនិយោគលើការបង្កាត់ពូជ ។ នៅខេត្តយ៉ាឡាយ ផលត្រីត្រូវបានប៉ាន់ស្មានថានាំមកនូវផលចំណូលជិត4លានដុល្លាអាមេរិកនៅឆ្នាំ 2010 ដែលកើនច្រើនជាង680% តែត្រឹមរយៈពេលបួនឆ្នាំមុន។[8] ទោះបីការលូតលាស់ឆាប់រហ័សក៏ដោយ តួលេខនេះនៅតែតូច បើធៀបនឹងវិស័យដទៃទៀត ដូចជា កសិកម្ម ដែលផ្តល់ចំណូលច្រើនជាង750លានដុល្លាសម្រាប់ខេត្តយ៉ាឡាយនៅឆ្នាំ2010។[9]

យ៉ាងហោចណាស់មានត្រី 89ប្រភេទ(66%)ដែលរកឃើញនៅទីនេះជាប្រភេទត្រីបំលាស់ទី និងពឹងផ្អែកលើភាពតជាប់គ្នានៃតំបន់ជិតខាង។[10] លើសពីនេះ ប្រភេទត្រីបំលាស់ទីទាំងនេះមានដល់ 60% នៃផលចាប់សរុប។[11] សហគមន៍តាមដងទន្លេសេសានពឹងផ្អែកជាខ្លាំងលើត្រីជាប្រភពប្រូតេអ៊ីន និងនៅកន្លែងខ្លះ សម្រាប់ជាផ្នែកសំខាន់មួយនៃប្រាក់ចំណូលរបស់ពួកគេ។

កសិកម្ម គឺជារបរចិញ្ចឹមជីវិតសំខាន់ជាងគេនៅក្នុងអាងទន្លេសេសាន រួមនិងមានការដាំដំណាំ ដូចជាស្រូវ ត្រាវ ដំឡូងមី កាហ្វេ ឈើហូបផ្លែ (ដូចជា ស្វាយចន្ទី និងស្វាយ) និងដំណាំសម្រាប់លក់ ដូចជា កៅស៊ូ។[12] នៅកម្ពុជា កង្វះហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពមានន័យថា ដំណាំនានាដូចជាស្រូវ មិនបានធ្វើជាទ្រង់ទ្រាយធំឡើយនៅក្នុងរដូវប្រាំង។ ក្នុងអាងទន្លេ3S ផ្នែកកម្ពុជាក្នុងប្រទេសកម្ពុជា (ដែលរួមទាំងសេកុងនិងស្រែពក) មានការប៉ាន់ស្មានថាចំណូលប្រចាំឆ្នាំ ដែលទាក់ទងនឹងអាងទន្លេនេះមាន 10លានដុល្លាអាមេរិក ក្នុងនោះ91%បានពីផលនេសាទ




*ប្រជាជនក្នុងអាងទន្លេ3S។ សេសុងមានប្រជាជនតិចជាងគេ ត្រូវជាប្រមាណ 7% នៃចំនួនប្រជាជនសរុបក្នុងអាងទន្លេ 3S។ ទិន្នន័យ LandScan 2012.*

ទឹកសាប។ ផ្ទុយទៅវិញ ផលស្រូវពីការស្រោចស្រពត្រូវបានប៉ាន់ស្មានថានាំមកនូវផលចំណូលតិចជាង 120.000ដុល្លាអាមេរិកក្នុងមួយឆ្នាំ ឬត្រឹមច្រើនជាង 1% ប៉ុណ្ណោះ នៃផល

---

6 Hong et al. 2013.
7 CNMC 2011, pg. 80.

8 Someth et al. 2013
9 Ibid.
10 Baran et al. 2011.
11 Ibid
12 Someth et al. 2013.

ចំណូលពីតំបន់នេះ។[13]

## ថាមពលវារីអគ្គិសនី

ដោយជួបប្រទះកង្វះអគ្គិសនីរួចមកហើយ ទាំងកម្ពុជា និងវៀត-ណាមបានសម្លឹងមើលវារីអគ្គិសនីថាជាប្រភពមួយនៃថាមពល។ វៀតណាមបានសាងសង់ទំនប់វារីអគ្គិសនីជាបន្តបន្ទាប់នៅក្នុងអាងទន្លេសេសាន ដែលរួមទាំង ទំនប់យ៉ាលី 720MW សង់នៅឆ្នាំ 1996។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកម្ពុជា (2009-2013) មានគោលដៅនាំយកអគ្គិសនីដល់ភូមិទាំងអស់រហូតអោយបានមុនឆ្នាំ 2020។ នេះមានន័យថា ជាការផ្តោតខ្លាំងលើថាមពលវារី-អគ្គិសនី។ ដើម្បីសម្រេចគោលដៅនេះ ប្រមាណជាជិត70% នៃសមត្ថភាពផលិតកម្មថាមពលរបស់កម្ពុជាត្រូវតែបានពីវារីអគ្គិ-សនី ដែលមួយផ្នែកធំបានពីភាគឦសាន ដែលរួមទាំង ទន្លេសេ-សានផងដែរ។

បច្ចុប្បន្ននេះ មានទំនប់វារីអគ្គិសនីខ្នាតមធ្យមនិងធំចំនួនប្រាំបីបានសង់លើអាងទន្លេនេះរួចហើយ និងមួយកំពុងសាងសង់នៅកម្ពុជានិងជាច្រើនទៀតកំពុងពិចារណាសម្រាប់អនាគត។ យ៉ាងហោចណាស់"រចនាសម្ព័ន្ធដើម្បីគ្រប់គ្រងដែលទាក់ទងនឹងទឹក" ចំនួន238 ដូចជា ទំនប់ស្ទាក់ទឹក និងអាងស្តុកទឹកខ្នាតតូច ដល់មធ្យម បានសាងសង់រួចមកហើយនៅអាងទន្លេសេសានភាគខាងលើ។[14]




*ទំនប់វារីអគ្គិសនីដែលមានស្រាប់(ក្រហម) និងគ្រោង និងកំពុងសាងសង់ (ពណ៌ទឹកក្រូច)។ទំហំតំណាងឲ្យសមត្ថភាពផលិត។ទិន្នន័យ៖ MRC 2009*

## ស្ថានភាពធនធានទឹក

ក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ បរិមាណទឹកទន្លេសេសានបានប្រែប្រួល ទាំងតាមរដូវនិងជារួម។ បញ្ហានេះបណ្តាលពី៖1) ការបូមយកទឹកពីទន្លេ ដើម្បីប្រើប្រាស់ក្នុងការស្រោចស្រព (ភាគច្រើនបាត់បង់តាមរំភាយចំហាយទឹក) និង 2) ការប្រែប្រួលរបបទឹកហូរបណ្តាលពីប្រពលវប្បកម្មកសិកម្ម (បង្កើនចំនួនរដូវប្រមូលផល និងប្តូរពី ដីគោកទៅកសិកម្មស្រោចស្រព) និងមួយផ្នែកតូច បណ្តាលពីកំណើនចំនួនប្រជាជន និងការអភិវឌ្ឍទីក្រុង និងឧស្សាហកម្ម។[15,16] គេនៅពុំទាន់យល់បានច្រើនពីធនធានទឹកក្រោមដីនៅឡើយប៉ុន្តែគេជឿថាកំពុងថយចុះយ៉ាងឆាប់រហ័សនៅក្នុងកន្លែងជាច្រើន។[17]

## ក្របខ័ណ្ឌច្បាប់ និងស្ថាប័នសំខាន់ៗ

ស្ថាប័នសំខាន់ៗគ្រប់គ្រងធនធានទឹក រួមមាន ក្រសួងធនធានធម្មជាតិនិងបរិស្ថាន (MONRE) ក្នុងប្រទេសនីមួយៗ ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ(MARD) ក្នុងប្រទេសវៀតណាម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅកម្ពុជា។ មានច្បាប់ផ្សេងៗគ្នាស្តីពីបរិស្ថាន ធនធានទឹក ដលផល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលមានឥទ្ធិពលមកលើធនធានទឹក ប៉ុន្តែស្ថិតក្នុងដែនសមត្ថកិច្ចតែក្នុងប្រទេសប៉ុណ្ណោះ។ យន្តការផ្លូវការចំបងសម្រាប់សហប្រតិបត្តិការអន្តររដ្ឋាភិបាលក្នុងអាងទន្លេមេគង្គគឺ គណៈកម្មការទន្លេមេគង្គ។ ប៉ុន្តែគ្មានកិច្ចព្រមព្រៀងជាមូលដ្ឋានដែលជាក់លាក់សម្រាប់អាងទន្លេនេះឡើយ ដែលចែងអំពីការគ្រប់គ្រង ឬអភិវឌ្ឍន៍ធនធានទឹកនៅក្នុងអាងទន្លេសេកុង។ ក្នុងន័យនេះ មធ្យោបាយការទូតមានសារៈសំខាន់ណាស់សម្រាប់គ្រប់គ្រងធនធានទឹកឆ្លងដែន។

នៅខែសីហាឆ្នាំ2014អនុសញ្ញាស្តីពីទឹករបស់សហប្រជាជាតិ (UNWC)[18]បានចូលជាធរមាននៅក្រោយវៀតណាមបានក្លាយជាហត្ថលេខីទី35។ អនុសញ្ញានេះមិនចូលជាធរមានសម្រាប់អាងទន្លេ 3Sដោយផ្ទាល់ឡើយ មុនពេលដែលប្រទេសជិតខាងផ្តល់សច្ចាប័ន។ ប៉ុន្តែ UNWC អាចដើរតួយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍទៅអនាគតនៅក្នុងតំបន់នេះ ដោយផ្តល់គោលការណ៍ណែនាំដែលបំពេញបន្ថែមលើកិច្ចព្រមព្រៀងមេគង្គឆ្នាំ1995។

[13] CNMC 2011, pg. 50.

[14] Viet Nam National Mekong Committee. (2003). Analysis of Sub-Area 7V. Basin Development Plan.

[15] ADB 2010.

[16] Cochrane 2010.

[17] CNMC 2011, pg. 19.

[18] UNWC 1997;formally titled the "U.N. Convention on the Law of Non-Navigational Uses of International Watercourses."

## ការគំរាមកំហែង និងបញ្ហាថ្មីៗ

មានការអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ នៅតាមផ្នែកនានានៃអាងទន្លេសេសាន ដែលនាំឲ្យមានការប្រែប្រួលគម្របដី ធនធានទឹក និងសេវាកម្មបរិស្ថាន។ ភាគច្រើនការអភិវឌ្ឍន៍ផ្តោតនៃការយកចិត្តទុកដាក់ទៅលើការសាងសង់ទំនប់ ជាពិសេស ទំនប់វារីអគ្គិសនីខ្នាតធំ ដែលមានផលបានប៉ះពាល់ដល់របបទឹកហូរនៃទន្លេសេសាន និងអាចប៉ះពាល់ដល់កន្លែងនានានៅខ្សែទឹកខាងក្រោមរហូតដល់ដែនដីសណ្តរទន្លេមេគង្គ ក៏ដូចជាជលផលនៅខ្សែទឹកខាងលើនៃទន្លេមេគង្គផងដែរ។ ទោះបីទំនប់ទាំងនេះផ្តល់ថាមពល និងការវិនិយោគជាច្រើនដែលចាំបាច់ក៏ដោយ ទំនប់បានធ្វើអោយមានកំណកល្បាប់ និងរាំងស្ទះដល់ចរាចរត្រីផងដែរ។

ការពង្រីកចំការដំណាំឧស្សាហកម្ម និងការស្តុកទឹកទុកក្នុងអាងសម្រាប់ទំនប់ បានកែប្រែកន្លែងនានាក្នុងអាងទន្លេសេសាន។ ការពង្រីកដំណាំកសិកម្មដទៃទៀត បានបន្ថែមសម្ពាធមកលើការបំប្លែងគម្របដីនេះ និងត្រូវបានគិតថាធ្វើឲ្យបាត់បង់ធនធានទឹកក្រោមដី។

ការធ្វើអាជីវកម្មក៏ជាកង្វល់នៃការប៉ះពាល់ដែលអាចកើតឡើងចំពោះគុណភាពទឹក និងគម្របដីផងដែរ។ អាងទន្លេសេសានមានកំណប់រ៉ែបុកស៊ីត ប្រាក់ និងត្បូងកណ្តៀង ដែលមកទល់ពេលនេះនៅពុំទាន់បានធ្វើអាជីវកម្មច្រើននៅឡើយទេ។

លើសពីនេះ តំបន់យ៉ាងធំនៅភាគខាងជើងនៃទន្លេសេសានត្រូវបានកំណត់ ជាចំណុចចាប់អារម្មណ៍សម្រាប់អាជីវកម្មរ៉ែមាសផងដែរ។ ប្រសិនបើតំបន់នេះត្រូវបានអភិវឌ្ឍណ៍ពេញលេញ វាអាចបង្កផលប៉ះពាល់អវិជ្ជមានចំពោះគុណភាពទឹកនៅតំបន់ខ្សែទឹកខាងក្រោម ជាពិសេស បណ្តាលពីជារទឹកលើដីដែលផ្សំដោយអាស៊ីតស្យានីក និងបារ៉ត។[19]

## ឯកសារយោង និងសម្រាប់អំណានបន្ថែម


Arias,M.E., Piman, T., Lauri, H., Cochrane, T.A., and Kummu, M. (2014). Dams on Mekong tributaries as significant contributors of hydrological alterations to the Tonle Sap Floodplain in Cambodia, Hydrol. Earth Syst. Sci. Discuss., 11, 2177-2209.

Asian Development Bank (ADB). (2010). Sesan, Sre Pok, and Sekong River Basins Development Study in Kingdom of Cambodia, Lao People’s Democratic Republic, and Socialist Republic of Viet Nam.

Baran, E., Saray Samadee, Teoh Shwu Jiau, Tran Thanh Cong. (2011). Fish and fisheries in the Sesan River Basin - Catchment baseline, fisheries section. Project report. Mekong Challenge Program project MK3 “Optimizing the management of a cascade of reservoirs at the catchment level”. WorldFish Center, Phnom Penh, Cambodia. 61 pp.

Cambodia National Mekong Committee (CNMC). (2011). Profile: Sub-area Sekong-Se San-Sre Pok Cambodia (SA-7C) (Unpublished draft: April 2011).

Cochrane, T. A., Arias, M. E., Teasley, R. L., & Killeen, T. J. (2010). Simulated changes in water flows of the Mekong River from potential dam development and operations on the Se San and Sre Pok tributaries.

Economic Consulting Associates. (2010). The Potential of Regional Power Sector Integration: Greater Mekong Sub-region (GMS) Transmission & Trading Case Study. London, 99 pps.

GlobCover. (2009). http://due.esrin.esa.int/globcover/. Global Land Cover Map for 2009 (GlobCover 2009). European Space Agency (ESA) & Université catholique de Louvain (UCL).

Hijmans et al. (2005). WorldClim Database. www.worldclim.org. Accessed 18 February 2014.

Hong Troung et al. (2013). Basin Profile of the Upper Sesan River. Project report: Challenge Program on Water & Food Mekong project MK3 “Optimizing the management of a cascade of reservoirs at the catchment level”. ICEM – International Centre for Environmental Management, Hanoi Vietnam, 2013.

LandScan. (2012). http://web.ornl.gov/sci/landscan/.

MRC. (2009). MRC Master Catalogue. http://portal.mrcmekong.org/master-catalogue.

Nagy, E. A., Maluski, H., Lepvrier, C., Schärer, U., Thi, P. T., Leyreloup, A., & Van Thich, V. (2001). Geodynamic Significance of the Kontum Massif in Central Vietnam: Composite 40Ar/39Ar and U-Pb Ages from Paleozoic to Triassic. The Journal of Geology, 109(6), 755-770.

Someth, P. et al. (2013). Basin Profile of the Lower Sekong, Sesan and Srepok (3S) Rivers in Cambodia. Project report: Challenge Program on Water & Food Mekong project MK3 “Optimizing the management of a cascade of reservoirs at the catchment level”. ICEM – International Centre for Environmental Management, Hanoi Vietnam, 2013.

Viet Nam National Mekong Committee (VNMC). (2010). Update of Sub-Area Profile: Sub-area 7V. Hanoi.

UNWC. (1997). http://legal.un.org/avl/ha/clnuiw/clnuiw.html


[19] CNMC pg. 74.

## BRIDGE: បង្កើតការសន្ទនា និងអភិបាលកិច្ចទន្លេ

ឯកសារនេះត្រូវបានបោះពុម្ពផ្សាយ ជាផ្នែកមួយនៃគម្រោង IUCN BRIDGE នៅក្នុងអាងទន្លេ 3S។

នៅក្រោមក្របខ័ណ្ឌនៃគម្រោងបង្កើតការសន្ទនានិងអភិបាលកិច្ចទន្លេ (BRIDGE) ដែលគាំទ្រដោយទីភ្នាក់ងារស្វ៊ីសដើម្បីអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC) អង្គការ IUCN (សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ) ប្រឹងប្រែងសម្រួលឲ្យមានដំណើរការសហប្រតិបត្តិការនៅក្នុងតំបន់ 3S ដោយបង្កើត និងពង្រឹងសមត្ថភាពអភិបាលកិច្ចទឹកតាមរយៈកំណែកម្មវិធីកែទម្រង់អភិបាលកិច្ចទឹក ការសន្ទនាជាមួយអ្នកពាក់ព័ន្ធ និងចែករម្លែកចំណេះដឹង។

## ចំពោះព័ត៌មានបន្ថែម

**Raphaël Glémet**
**Senior Programme Officer, Water and Wetlands**
E-mail: raphael.glemet@iucn.org
IUCN Asia Regional Office (ARO)

## វេបសាយ

BRIDGE 3S Basins website: www.3sbasin.org
IUCN BRIDGE websites: www.iucn.org/bridge
www.iucn.org/about/union/secretariat/offices/asia/regional_activities/bridge_3s/

## អំពីអង្គការ IUCN

អង្គការ IUCN ជួយពិភពលោកក្នុងការស្វែងរកដំណោះស្រាយជាក់ស្តែងតបនឹងការប្រឈមបន្ទាន់បំផុតរបស់យើងខាងបរិស្ថាន និងការអភិវឌ្ឍ។

ការងាររបស់អង្គការ IUCN ផ្តោតលើការវាយតម្លៃ និងការអភិរក្សធម្មជាតិ ការធានាឲ្យមានអភិបាលកិច្ចយ៉ាងមានប្រសិទ្ធភាព និងសមធម៌លើការប្រើប្រាស់ធនធានធម្មជាតិ និងការដាក់ឲ្យអនុវត្តដំណោះស្រាយផ្អែកលើធម្មជាតិ ចំពោះការប្រឈមនានាក្នុងពិភពលោក ខាងអាកាសធាតុ ស្បៀង និងការអភិវឌ្ឍ។ អង្គការ IUCN គាំទ្រដល់ការស្រាវជ្រាវវិទ្យាសាស្ត្រ គ្រប់គ្រងគម្រោងនៅតាមមូលដ្ឋានទូទាំងពិភពលោក និងអញ្ជើញរដ្ឋាភិបាល, អង្គការមិនមែនរដ្ឋាភិបាល, អង្គការសហប្រជាជាតិ និងក្រុមហ៊ុននានា មកធ្វើការជាមួយគ្នា ដើម្បីបង្កើតគោលនយោបាយ ច្បាប់ និងទម្លាប់ល្អ។

ការិយាល័យប្រចាំតំបន់អាស៊ីនៃអង្គការ IUCN ស្ថិតនៅក្នុងក្រុងបាងកក ប្រទេសថៃ ជាមួយកម្មវិធីតាមប្រទេស និងការិយាល័យទំនាក់ទំនងនៅក្នុងប្រទេសបង់ក្លាដែស កម្ពុជា ចិន ឥណ្ឌា ឡាវ នេប៉ាល់ ប៉ាគីស្ថាន ស្រីលង្កា ថៃ និងវៀតណាម។

**www.iucn.org**
**www.iucn.org/asia**
**Facebook: iucn.asia   Twitter: iucnasia**